មជ្ឈមណ្ឌល ត្រួតពិនិត្យ និង ការពារជម្ងឺ

ប្រភពបណ្តាញទាក់ទងសម្រាប់ព័ត៌មានសុខភាពដែលជាទីទុកចិត្តរបស់លោកអ្នក

សំណួរដែលសាកសួរជាញឹកញាប់

តើមានអ្វីខ្លះ នៅក្នុងប្រេង ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់?

ប្រេងធ្លាយហៀរ អាចមានធាតុផ្សំប្រេងពីរប្រភេទ: ប្រេងម៉ាស៊ូត និង ប្រេងនៅ។ ប្រេងនៅ ដែលគេជឿថា វាបង្កើតឡើងនូវផ្នែកយ៉ាងធំនៃប្រេងប្រេងធ្លាយហៀរ ពីព្រោះប្រេងនៅនេះ អាចចេញមកពីអណ្តូងប្រេង ដែលមានជម្រៅ 5000 feet (ហ្វីត) (1 ហ្វីត មានប្រវែង 0.3048 ម៉ែត្រ) នៅខាងក្រោមផ្ទៃសមុទ្រ។

ប្រេងម៉ាស៊ូត និង ប្រេងនៅ គឺជាការលាយចូលនូវសារធាតុខុសៗគ្នារវាង អ៊ីដ្រូហ្សែន និង កាបូន ដោយផ្អែកលើសារធាតុគីមីធម្មតា ដែលគេហៅថា អ៊ីដ្រូកាបូន។ ដោយសារ សារធាតុលាយចូលគ្នា ដូចនេះ ប្រេងដែលមានប្រភេទខុសៗគ្នានោះ អាចបណ្តាលឱ្យគ្រោះថ្នាក់ដល់សុខភាព ទៅតាមរបៀបខុសៗគ្នាជាច្រើន។

ប្រេងម៉ាស៊ូត ពិបាកដុតវា ជាងប្រេសាំងប្រើប្រាស់ប្រចាំថ្ងៃ ហើយវាស្ថិតនៅយ៉ាងយូរនៅក្នុងបរិស្ថាន នៅពេលណា វាបានធ្លាយហៀរ។ ប្រេងម៉ាស៊ូតនេះ ប្រសិនបើ វាបានបញ្ចេញមកពីអណ្តូងប្រេងដែលខួងនោះ វាចូលទៅក្នុងខ្យល់យ៉ាងយឺតៗ ហើយគេអាចដឹងបានដោយសារក្លិន បើទោះជា ដំណក់ប្រេងម៉ាស៊ូតដ៏តូច ស្ថិតនៅក្នុងខ្យល់ក៏ដោយ។

ប្រេងនៅ ដែលពាក់ព័ន្ធនឹងការធ្លាយហៀរប្រេងនេះ គឺអ្វីដែលគេហៅថា ប្រេងនៅផ្អែមមធ្យម។

"ផ្អែម" មានន័យថា វាផ្សំទៅដោយសមាសធាតុស្ពាន់ធ័រតិចតូច ដែលមានន័យថា វាមានជាតិពុលតិចតូច។ ប្រេងនៅមធ្យម តាមធម្មតាវាផ្សំឡើងដោយសារធាតុគីមីចំនួនពីរបី ដែលងាយចូលទៅក្នុងខ្យល់ ដូចគ្នាទៅនឹងប្រភេទប្រេងផ្សេងៗទៀតដែរ។ ប្រេងនៅមធ្យម មានធាតុផ្សំគីមីចំនួនពីរបី ដែលបង្កើតឱ្យមានបញ្ហាអស់រយៈពេលយ៉ាងយូរ នៅក្នុងសភាពផ្ទុយគ្នាចំពោះប្រភេទប្រេងផ្សេងៗទៀត។

ដោយផ្អែកលើទិន្និន័យ ពីប្រេងដែលបានរុករកឃើញពីអណ្តូងប្រេងផ្សេងៗទៀត នៅក្នុងតំបន់នេះ យើងសង្ឃឹមថា មានសារធាតុដែលអាចគ្រោះថ្នាក់ជាច្រើនថែមទៀត បានត្រូវគេរកឃើញនៅក្នុងប្រេងនៅ ដូចជាបង់ហ្សែន(ឧស្ម័នម៉ូាង) និង សមាសធាតុស្ពាន់ធ័រនិងធាតុគីមីផ្សេៗទៀត នឹងបង្កើតឡើងចំនួនតិចជាង 1% នៃការធ្លាយហៀរប្រេងនេះ។

តើមានអ្វីខ្លះ នៅក្នុងខ្យល់?

លើសពីនេះ សមាសធាតុជាច្រើន ដែលបង្កើតការលាយចូលគ្នាទាំងនេះ នឹងចូលទៅក្នុងខ្យល់។ បន្ទាប់មក ខ្យល់នឹងធ្វើឱ្យាសាយភាយចំហាយនានាទៅឆ្ងាយៗ ដែលធ្វើឱ្យចុះទាបនូវការប្រមូលផ្សុំសមាសធាតុរបស់វា នៅក្នុងតំបន់ណាមួយ។

នៅពេលណា ចំហាយទាំងនេះ មកដល់តាមផ្នែរសមុទ្រ លោកអ្នក នឹងអាចធុំក្លិនសមាសធាតុទាំងនោះ។ ដោយផ្អែកលើអ្វី ដែលយើងដឹងអំពី សារធាតុគីមីទាំងនេះ និង បទពិសោធន៍នានាកន្លងមករបស់យើង ជាមួយនឹងការធ្លាយហៀរប្រេងនេះ យើងសង្ឃឹមថា កម្រិតនៃចំហាយនៅក្នុងខ្យល់ នឹងទាបជាងកម្រិតដែលអាចធ្វើឱ្យខូចខាតសុខភាពលោកអ្នក។ ការធ្វើតេស្តនានានៃខ្យល់ អាចប្រាប់យើងអំពីបញ្ហាជាច្រើនថែមទៀត។

ក្លិនដែលខ្លាំង មានផលប៉ះពាល់ចំពោះប្រជាពលរដ្ឋខុសៗគ្នា ទៅតាមរបៀបផ្សេងៗគ្នា។ ប្រជាពលរដ្ឋមួយចំនួន អាចជួបប្រទះនឹង ការឆ្អើមចង់ក្អួត ការក្អួត ឬ ឈឺក្បាល។ លោកអ្នក ចាកចេញពីតំបន់ដែលរងនូវផលប៉ះពាល់ ដោយសារក្លិននេះ វាគួរតែជួយបញ្ឈប់ពីរោគសញ្ញានានារបស់លោកអ្នក ប្រសិនបើ ក្លិននេះ បណ្តាលមកពីសារធាតុទាំងនោះ។ ប្រសិនបើ លោកអ្នកត្រូវការទៅក្រៅផ្ទះឬក្រៅអាគារ លោកអ្នក អាចប្រើប្រាស់ម៉ាស់ពាក់មុខ សម្រាប់ជួយដកដង្ហើមបំពាក់ជាមួយសម្ភារៈគ្រប់គ្រងក្លិន អាចផ្តល់ជូននូវការបន្ធូរបន្ថយបញ្ហាដែលចេញពីក្លិននេះ។ ដោយផ្អែកលើអ្វី ដែលយើងដឹងឥឡូវនេះ លោកអ្នកមិនត្រូវការប្រើប្រាស់ ម៉ាស់ពាក់មុខសម្រាប់ជួយដកដង្ហើមសម្រាប់សុវត្ថិភាពរបស់លោកអ្នកនោះទេ ប៉ុន្តែ ការប្រើប្រាស់វានោះ អាចធ្វើឱ្យលោកអ្នកមានអារម្មណ៍សុខសាន្តថែមទៀត។ សន្និធិលក់សម្ភារៈ NIOSH ភាគច្រើន ដែលបានបញ្ជាក់ដោយ ម៉ាស់ពាក់មុខសម្រាប់ជួយដកដង្ហើម N95 បំពាក់ជាមួយសម្ភារៈគ្រប់គ្រងក្លិន ឬ ស្រទាប់តម្រងជាតិធ្យូង មានការត្រួតពិនិត្យស្លាក ដើម្បីធានាថា ម៉ាស់នោះ គឺម៉ាស់ពាក់មុខសម្រាប់ជួយដកដង្ហើម N95 បំពាក់ជាមួយសម្ភារៈគ្រប់គ្រងក្លិន ឬ N95 ស្រទាប់តម្រងជាតិធ្យូង។ សូមលោកអ្នក គោរពទៅតាមសេចក្តីណែនាំនានារបស់ឧស្សាហកម្មដោយប្រុងប្រយ័ត្ន ដើម្បីធានាថា លោកអ្នក កំពុងតែប្រើប្រាស់ម៉ាស់នេះយ៉ាងសមរម្យ។

សម្រាប់ពេលឥឡូវនេះ ប្រសិនបើ មានក្លិនរំខានលោកអ្នក សូមលោកអ្នកនៅក្នុងផ្ទះ បិទទ្វារ និង បង្អួច ហើយ បើកម៉ាស៊ីនត្រជាក់ដែលនៅចំកណ្តាលលោកអ្នក។ ប្រសិនបើ លោកអ្នកមានម៉ាស៊ីនត្រជាក់ដែលនៅជាប់នឹងបង្អួច សូមប្រើប្រាស់វាជំនួសម៉ាស៊ីនត្រជាក់ដែលនៅចំកណ្តាលនោះវិញ ហើយអាចល្អជាងនេះទៅទៀត សូមកុំប្រើប្រាស់ម៉ាស៊ីនត្រជាក់ ឬ បើកឱ្យកើតមានឡើងតាមរបៀបខ្យល់ឬហ្គាសចេញចូលទៅវិញទៅមក ពេលដែលបិទកង្ហារខាងក្រៅនោះ។

តើមានអ្វីខ្លះ នឹងមកលើគោក ជាមួយប្រេងនេះ?

វា នឹងចំណាយពេលវាលាសម្រាប់ប្រេង ដើម្បីមកដល់លើគោកនោះ។ នៅក្នុងកំឡុងពេលនេះ យើងកុំពុងតែធ្វើប្រតិបត្តិការបំបែកប្រេង ដោយប្រើប្រាស់សារធាតុគីមីរផ្សេងៗទៀត ដូចនេះ វាមានប្រេងតិចតួចណាស់ដែលមកដល់លើគោក។ តាមធម្មតា ប្រេងនេះ គឺធ្វើឱ្យរងនូវគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះសត្វព្រៃ ច្រើនជាងមនុស្ស។ លោកអ្នក នឹងឮអំពីគ្រោះថ្នាក់ដល់សត្វព្រៃច្រើនថែមទៀត នៅពេលប្រតិបត្តិការបោសសំអាតនេះ កុំពុងតែបន្តនោះ។

រាល់សារធាតុគីមីនានា ចេញពីប្រេង ដែលពិតជាបានមកដល់លើគោកនោះ វាអាចមានធុំក្លិន និង មើលទៅហាក់ដូចជា កៅស៊ូខ្មៅៗ ឬ កៅស៊ូក្រាលថ្ម។ ហើយនេះ មានសារៈសំខាន់ណាស់ សូមលោកអ្នកនៅឱ្យឆ្ងាយពីប្រេងណាមួយ ដែលមកដល់លើគោក ពីព្រោះ នៅពេលណាយើងចូលជិត ប្រឡាក់ជាមួយប្រេងអស់រយៈពេលយូរនោះ វាអាចបណ្តាលឱ្យមានគ្រោះថ្នាក់កើតឡើង។ សូមលោកអ្នក ជៀសវាង កុំប៉ះពាល់ប្រេង ប្រសិនណា លោកអ្នកឃើញវានោះ។

ប្រសិនណា មានប្រេងខ្លះ ប្រឡាក់ស្បែករបស់លោកអ្នក សូមលាងដៃចេញយ៉ាងឆាប់រហ័សដែលលោកអ្នកអាចធ្វើទៅបាន។ ប្រសិនណា លោកអ្នកមានស្នាមកន្ទួលក្រហមនោះ សូមលោកអ្នកទៅជួបវេជ្ជបណ្ឌិត ឬ អ្នកផ្តល់សេវាកម្មថែទាំសុខភាពផ្សេងៗទៀត។ សូមលោក អ្នកប្រាប់ពួកគេ ថាតើ លោកអ្នក ប៉ះពាល់ប្រេងនេះយ៉ាងដូចម្តេច ហើយបន្ទាប់មក សូមឱ្យអ្នកផ្តល់សេវាកម្មថែទាំសុខភាពរបស់លោកអ្នក ទាក់ទងនៅមជ្ឈមណ្ឌលត្រួតពិនិត្យជាតិពុល តាមរយៈលេខទូរស័ព្ទ: 1-800-222-1222។

តើប្រេង អាចធ្វើឱ្យមានគ្រោះថ្នាក់ដល់កូនរបស់ខ្ញុំឬទេ?

កុមារៗ ងាយរងនូវបញ្ហានេះ ជាងមនុស្សពេញវ័យ ចំពោះការប៉ះពាល់ប្រេង និង វត្ថុក្រខ្វក់ផ្សេងៗទៀត។ តើមានអ្វី ធ្វើឱ្យរំខានចំពោះលោកអ្នក ដែលអាចជាបញ្ហាមួយជាក់លាក់សម្រាប់ពួកគេនោះ ជាពិសេស នៅពេលដែលកូនរបស់លោកអ្នក ជាកុមារ ឬ កូនងែតតូចៗ ឬ ល័ក្ខ័ណ្ឌដែលកើតមានពីមុនៗមកនោះ។

មនុស្សពេញវ័យ កុមារៗ គួរតែជៀសវាងការប៉ះពាល់ជាមួយប្រេង។ ប្រសិនណា មានប្រេងខ្លះ ប្រឡាក់លើស្បែកកុមាររបស់លោកអ្នក សូមលាងដៃចេញយ៉ាងឆាប់រហ័សដែលលោកអ្នកអាចធ្វើទៅបាន។ សូមមើលកុមាររបស់លោកអ្នកដោយប្រុងប្រយ័ត្ន ចំពោះការចេញកន្ទួល ឬ ស្នាមខ្មៅ ស្នាមអុចៗ នៅលើស្បែករបស់ពួកគេ ដែលពិបាកលាងចេញនោះ។ ប្រសិនណាលោកអ្នក ឃើញរោគសញ្ញាទាំងនេះ សូមលោកអ្នកទៅជួបវេជ្ជបណ្ឌិត ឬ អ្នកផ្តល់សេវាកម្មថែទាំសុខភាពផ្សេងៗទៀត។

តើខ្ញុំ អាចទទួលព័ត៌មានបន្ថែមទៀតនៅឯណា?

សម្រាប់ព័ត៌មានបន្ថែមអំពី ការធ្លាយហៀរប្រេង និង ដំណើរការវិវត្តន៍នៃការបោសសំអាត សូមលោកអ្នកមើលលើគេហទំព័រ www.deepwaterhorizonresponse.com។

សម្រាប់ព័ត៌មានបន្ថែមអំពី គ្រោះថ្នាក់នានាដែលជាសក្តានុពល ដែលពាក់ព័ន្ធនឹងប្រេង និង ផលិតផលប្រេងឥន្ធន:នានា សូមលោកអ្នកមើលលើគេហទំព័រ http://emergency.cdc.gov/gulfoilspill2010/។

មជ្ឈមណ្ឌល ត្រួតពិនិត្យ និង ការពារជម្ងឺ1600 Clifton Rd. Atlanta, GA 30333, USA
800-CDC-INFO (800-232-4636) TTY: (888) 232-6348, 24 ម៉ោងក្នុងមួយថ្ងៃ-
cdcinfo@cdc.gov